**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** : ០៧៥/២៦ **ក.ប**/ស.ជ.ណ.ម.ក

# សេចក្តីជូនដំណឹង
## ស្តីពី
## ការស្នើសុំការអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេសសម្រាប់ឆ្នាំ២០២៧

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដល់ម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រ ទាំងអស់ ដែលស្ថិតក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារឱ្យបានជ្រាបថា ដើម្បីអាចប្រើប្រាស់ហត្ថពលកម្មបរទេសសម្រាប់ឆ្នាំ២០២៧ ម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេស **ចាប់ពីថ្ងៃទី១ ខែកញ្ញា រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៦** ក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្លាំងពលកម្មបរទេស (The Foreign Workers Centralized Management System – FWCMS) តាមរយៈគេហទំព័រ https://fwcms.mlvt.gov.kh/។ ចំពោះសហគ្រាស ក្រុមហ៊ុន រោងចក្រ ដែលបើកដំណើរការក្រោយកាលបរិច្ឆេទនេះ ហើយមានតម្រូវការប្រើប្រាស់ហត្ថពលកម្មបរទេសអាចស្នើសុំប្រើប្រាស់ហត្ថពលកម្មបរទេសភ្លាមៗ បន្ទាប់ពីសហគ្រាស ក្រុមហ៊ុន រោងចក្រនោះមានដំណើរការ។

បន្ថែមពីលើនេះ ដើម្បីឱ្យមានបញ្ជីឈ្មោះកម្មករនិយោជិតបរទេសដោយស្វ័យប្រវត្តិក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្លាំងពលកម្មបរទេស (FWCMS) ក្រសួងសូមក្រើនរំលឹកដល់ម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រ ត្រូវធ្វើការតភ្ជាប់ប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារ (LACMS) និងប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្លាំងពលកម្មបរទេស (FWCMS) សូមស្កេន QR Code ខាងក្រោមដើម្បីទាញយកឯកសារ "របៀបតភ្ជាប់ប្រព័ន្ធ LACMS និង FWCMS របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ"។

ក្រសួងសូមបញ្ជាក់ថា ជនបរទេសដែលចូលមកស្នាក់នៅនិងប្រកបមុខរបរ ឬធ្វើការនៅព្រះរាជាណាចក្រកម្ពុជា ត្រូវស្នើសុំបណ្ណការងារនិងសៀវភៅការងារជនបរទេសតាមរយៈប្រព័ន្ធFWCMS ក្នុងរយៈពេល ៩០ថ្ងៃយ៉ាងយូរ គិតចាប់ពីកាលបរិច្ឆេទដំបូងដែលបានចូលមកព្រះរាជាណាចក្រកម្ពុជា។

ក្នុងករណីម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រដែលប្រើប្រាស់ហត្ថពលកម្មបរទេសមិនបានស្នើសុំការអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេសសម្រាប់ឆ្នាំ២០២៧ ឬជនបរទេសមិនបានស្នើសុំបណ្ណការងារនិងសៀវភៅការងារជនបរទេសតាមកាលបរិច្ឆេទកំណត់ខាងលើ ត្រូវរងការផាកពិន័យជាប្រាក់ និងចំណាត់ការពីអធិការការងារស្របតាមច្បាប់ជាធរមាន។

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រ ទាំងអស់នឹងអនុវត្តឱ្យបានត្រឹមត្រូវតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាព។

ថ្ងៃ ចន្ទ ៣រោច ខែស្រាពណ៍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៦

**រដ្ឋមន្ត្រី**

**ហេង សួរ**

"**របៀបតភ្ជាប់ប្រព័ន្ធ** LACMS **និង**FWCMS"

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
- គ្រប់សមាគមនិយោជក
- ឯកសារ កាលប្បវត្តិ